# សេចក្តីថ្លែងការណ៍រួម

*រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៦*

## អង្គការសង្គមស៊ីវិលសូមប្រកាសគាំទ្រអង្គការមាតាធម្មជាតិ និងថ្កោលទោសចំពោះការបង្ក្រាបទៅលើអង្គការនេះ

ជាការឆ្លើយតបទៅនឹងបទចោទយ៉ាងអយុត្តិធម៌ចុងក្រោយបង្អស់ប្រឆាំងទៅលើសមាជិកបីរូបបន្ថែមទៀតរបស់អង្គការការពារបរិស្ថានឈ្មោះមាតាធម្មជាតិ យើងជាអង្គការសង្គមស៊ីវិលដូចមានរាយនាមខាងក្រោម សូមប្រកាសគាំទ្រអង្គការមាតាធម្មជាតិ និងសូមថ្កោលទោសចំពោះចំណាត់ការរបស់រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ក្នុងការបង្ក្រាបទៅលើអង្គការនេះ និងសង្គមស៊ីវិលទូទៅនៅកម្ពុជា។

សមាជិកអង្គការមាតាធម្មជាតិចំនួនបីរូប ដែលត្រូវបានចោទប្រកាន់រួមមាន ព្រះសង្ឃពីរអង្គដែលពុំមានជាប់ពាក់ព័ន្ធទៅនឹងសកម្មភាពប្រចាំថ្ងៃ ឬយុទ្ធនាការដែលរៀបចំដោយអង្គការមាតាធម្មជាតិ។ ព្រះសង្ឃទាំងពីរអង្គរួមមាន ព្រះតេជគុណព្រះនាម សុខ ចាន់ត្រា ព្រះជន្ម ២៤ វស្សា ជាព្រះចៅអធិការវត្ត អង្គគីរី ស្ថិតនៅក្នុងឃុំប្រឡាយ (ជ្រលងអារ៉ែង) ខេត្តកោះកុង និងជាលេខាធិការរបស់អង្គការមាតាធម្មជាតិ និងព្រះតេជគុណ ព្រហ្ម ធម្មជាតិ ជានាយកប្រតិបត្តិកិត្តិយសរបស់អង្គការមាតាធម្មជាតិ ។ ព្រះតេជគុណទាំងពីរអង្គនោះគ្មានអំណាចសម្រេចនៅក្នុងសកម្មភាពការងាររបស់អង្គការមាតាធម្មជាតិឡើយ។

សមាជិកទីបីរបស់អង្គការមាតាធម្មជាតិដែលរងការចោទប្រកាន់នោះគឺលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដាវីដសុន សញ្ជាតិអេស្ប៉ាញ ជាស្ថាបនិក និងជានាយកនៃអង្គការមាតាធម្មជាតិ។ បច្ចុប្បន្ននេះ លោក អាឡិចហ្សង់ដ្រូ កំពុងស្ថិតនៅក្នុងការនិរទេសខ្លួនដែលត្រូវបានបណ្តេញចេញពីកម្ពុជាដោយបង្គំតាមការបញ្ជារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន រយៈពេលជិតមួយឆ្នាំមកហើយ។ ការបណ្តេញចេញ លោក អាឡិចហ្សង់ដ្រូ ជាការសងសឹកដោយផ្ទាល់ចំពោះសកម្មនិយមក្នុងការងារបរិស្ថានរបស់លោកជាយូរណាស់មកហើយប្រឆាំងនឹងការសាងសង់ទំនប់វារីអគ្គិសនីឆាយអារ៉ែងនៅក្នុងខេត្តកោះកុង។ បើទោះបីជាបទចោទប្រកាន់ត្រូវបានប្រកាសជាសាធារណៈកាលពីថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ក៏ដោយ ក៏សាលាដំបូងខេត្តកោះកុងមិនទាន់មានការជូនដំណឹងជាផ្លូវការដល់ជនជាប់ចោទទាំងបីអង្គ នាក់ ទាក់ទិននឹងបទចោទនៅឡើយទេ ដែលនេះជាការគំរាមដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ពួកគាត់។

យើងជាអង្គការសង្គមស៊ីវិល សូមសំដែងការគាំទ្រយ៉ាងពេញទំហឹងចំពោះការទាមទាររបស់លោក អាឡិចហ្សង់ដ្រូ នូវសិទ្ធិការពារខ្លួនដោយផ្ទាល់ដូចដែលបានធានាតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ការតម្រូវឲ្យជនត្រូវចោទបង្ហាញខ្លួននៅចំពោះមុខតុលាការត្រូវបានតម្រូវបន្ថែមតាមមាត្រា ៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ បច្ចុប្បន្ននេះ លោក អាឡិចហ្សង់ដ្រូ ត្រូវបានហាមប្រាមចូលមកប្រទេសកម្ពុជារហូតទាល់តែមានការអនុញ្ញាតពីក្រសួងមហាផ្ទៃ ឬក៏ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ជាងនេះទៅទៀត យើងសូមអំពាវនាវ

ឲ្យមានការជូនដំណឹងជាផ្លូវការជាបន្ទាន់ទាក់ទងនឹងបទចោទទៅលើជនជាប់ចោទទាំងបីអង្គ នាក់ ដើម្បីជានាឲ្យមានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

បុគ្គលទាំងបីអង្គ នាក់ ជាប់ចោទពីបទសមគំនិត ក្រោមមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌនិងបទល្មើសក្រោមមាត្រា ៤២៤ ពីបទ *"គំរាមកំហែងថានឹងធ្វើឱ្យខូចខាតដែលភ្ជាប់មកនូវបញ្ជាអ្វីមួយ"* ដែលអាចនឹងត្រូវផ្តន្ទាទោសជាប់ពន្ធនាគាររហូតដល់ទៅ ២ ឆ្នាំ ។ ការចោទប្រកាន់ទាំងនេះគឺដូចគ្នាទៅនឹងបទចោទប្រឆាំងនឹងសកម្មជនរបស់អង្គការមាតាធម្មជាតិចំនួនបីរូបគឺ លោក ទ្រី សុវិកា លោក ស៊ុន ម៉ាឡា និងលោក ស៊ឹម សំណាងដែរ ដែលត្រូវបានឃុំខ្លួនក្នុងពន្ធនាគារខេត្តកោះកុងចាប់តាំងពីថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១៥ និងចោទប្រកាន់តាមមាត្រា ៤២៤។ សកម្មជនដែលជាប់ពន្ធនាគារទាំងបីរូបនោះបានចូលរួមក្នុងការតវ៉ាប្រឆាំងទៅនឹងការបូមខ្សាច់ដែលត្រូវបានចោទថាជាការបូមខុសច្បាប់ក្នុងស្រុកបទុមសាគរ ខេត្តកោះកុង។ សម្រាប់ព័ត៌មានបន្ថែមពីសាវតារអង្គការមាតាធម្មជាតិនិងការបង្ក្រាបនាពេលថ្មីៗប្រឆាំងនឹងសកម្មជនទាំងនោះ សូមមើលសលាកប័ត្រព័ត៌មានដែលបានចេញផ្សាយនាពេលថ្មីៗដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក")។

ការចោទប្រកាន់ថ្មីៗទាំងនេះគឺជាករណីចុងក្រោយបង្អស់ក្នុងចំណោមករណីចាប់ខ្លួន និងព្រឹត្តិការណ៍នានាជាច្រើនដែលអាជ្ញាធរបានធ្វើទុកបុកម្នេញម្តងហើយម្តងទៀត និងមានចេតនាបង្ក្រាបទៅលើចលនាមាតាធម្មជាតិទាំងស្រុង។ ក្រោយពីការបណ្តេញលោក អាឡិចហ្សង់ដ្រូ ចេញដោយជោគជ័យក្នុងខែកុម្ភៈ ឆ្នាំ២០១៥ អាជ្ញាធរបានចាប់ខ្លួនសមាជិកអង្គការជាច្រើននាក់ទៀត ដោយសារពួកគេជាប់ពាក់ព័ន្ធក្នុងការធ្វើបាតុកម្មសកម្មនិយម និងសកម្មភាពអប់រំផ្សេងៗ។ ការគាបសង្កត់ទៅលើកិច្ចប្រឹងប្រែងក្នុងការការពារបរិស្ថានរបស់អង្គការមាតាធម្មជាតិគឺបង្ហាញឱ្យឃើញពីការបង្ក្រាបកាន់តែធំៗ ទៅលើសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា និងភាពមិនអត់ឱនរបស់រាជរដ្ឋាភិបាលចំពោះសកម្មនិយមដោយសន្តិវិធីស្របតាមច្បាប់។

ការបន្តដាក់លោក អាឡិចហ្សង់ដ្រូ ក្នុងបញ្ជីខ្មៅ និងការកាត់ទោស និងដាក់ទោសលោកកំបាំងមុខនឹងបង្កការរំលោភបំពានយ៉ាងធ្ងន់ធ្ងរដល់សិទ្ធិជំនុំជម្រះដោយយុត្តិធម៌របស់លោក។ លោក អាឡិចហ្សង់ដ្រូ ទាមទារសិទ្ធិការពារខ្លួនលោក និងសិទ្ធិឆ្លើយតបរាល់ការចោទប្រកាន់នៅចំពោះមុខចៅក្រម មិនថាមានផលវិបាកអ្វីក៏ដោយ។ យើងខ្ញុំសូមគាំទ្រយ៉ាងពេញទំហឹងចំពោះការទាមទារត្រឡប់មកវិញរបស់លោកអាឡិចហ្សង់ដ្រូ។

ស្ថាបនិកអង្គការមាតាធម្មជាតិ លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេស ដេវីដសុន មានប្រសាសន៍ថា ៖

*"ខ្ញុំទាមទារសិទ្ធិរបស់ខ្ញុំដើម្បីការពារខ្លួននៅក្នុងតុលាការតទល់នឹងការចោទប្រកាន់គ្មានមូលដ្ឋានទាំងនេះ ដែលទាំងនេះគ្មានអ្វីក្រៅតែពីការសងសឹកមកលើរូបខ្ញុំ និងសកម្មជនដទៃទៀតនោះទេ ដោយសារយុទ្ធនាការដ៏មានប្រសិទ្ធិភាពរបស់យើងក្នុងការបញ្ឈប់ការបំផ្លាញធម្មជាតិនៅកម្ពុជា។ វាជាតួនាទីរបស់ខ្ញុំដែលត្រូវធ្វើនូវអ្វីដែលខ្ញុំអាចធ្វើបាន នៅក្បែរពួកគេ ហើយទាមទារឱ្យផ្តល់នូវយុត្តិធម៌ដល់យើងខ្ញុំគ្រប់គ្នា មិនថាមានបញ្ហាលំបាកយ៉ាងណានៅក្នុងប្រព័ន្ធយុត្តិធម៌បច្ចុប្បន្ននោះទេ។"*

យើងជាអង្គការសង្គមស៊ីវិលដូចមានរាយនាមខាងក្រោម សូមស្នើដល់ព្រះរាជអជ្ញាមេត្តាទម្លាក់ចោលការចោទប្រកាន់ដោយអយុត្តិធម៌ពីបទញុះញង់និងគំរាមកំហែងថានឹងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ទៅលើ

សមាជិកអង្គការមាតាធម្មជាតិទាំងប្រាំមួយនាក់ ហើយសូមជានាការពារឱ្យបានត្រឹមត្រូវដល់សកម្មជនបរិស្ថាន និងអ្នកការពារសិទ្ធិមនុស្សទាំងឡាយដែលប្រឹងប្រែងក្នុងការការពារធនធានធម្មជាតិនៅកម្ពុជាដែលជាទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់ពលរដ្ឋកម្ពុជា។

ម្យ៉ាងទៀត យើងខ្ញុំសូមអំពាវនាវដល់ក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិមេត្តាគោរពតាម និងធានាដល់សិទ្ធិជំនុំជម្រះដោយយុត្តិធម៌ ដែលត្រូវបានទទួលស្គាល់នៅថ្នាក់ជាតិ និងអន្តរជាតិ ដោយអនុញ្ញាតឱ្យលោក អាឡិចហ្សង់ដ្រូ បានវិលត្រឡប់មកកម្ពុជាវិញដើម្បីអនុវត្តសិទ្ធិការពារខ្លួនតទល់នឹងការចោទប្រកាន់ទាំងនេះ។

អង្គការសង្គមស៊ីវិលដែលគាំទ្រសេចក្ដីថ្លែងការណ៍នេះ រួមមាន ៖

| *ល.រ* | *ឈ្មោះអង្គការ សមាគម* | *ឈ្មោះអ្នកទំនាក់ទំនង* | *លេខទំនាក់ទំនង* |
|---|---|---|---|
| ១ | *ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)* | *កញ្ញា ស្រី សុជាវី* | 017 990 371 |
| ២ | *សម្ព័ន្ធគណនេយ្យភាពសង្គមកម្ពុជា (ANSA)* | *លោក សន ជ័យ* | 012 445 652 |
| ៣ | *សម្ព័ន្ធសហជីពកម្ពុជា (CATU)* | *លោកស្រី យ៉ាង សោភណ្ឌ* | 089 33 66 01 |
| ៤ | *មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)* | *លោកស្រី ឆាយ ឈុនលី* | 017 528 021 |
| ៥ | *មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)* | *លោក ប៉ា ងួនទៀង* | 012 598 066 |
| ៦ | *សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)* | *លោក ធន់ សារ៉ាយ* | 016 440 044 |
| ៧ | *សហភាពការងារកម្ពុជា (CLC)* | *លោក អាត ធន់* | 012 998 906 |
| ៨ | *សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)* | *អ្នកនាង ណាលី ពីឡូក* | 012 803 650 |
| ៩ | *សម្ព័ន្ធដើម្បីសុចរិតភាព និង គណនេយ្យភាពសង្គម (CISA)* | *លោក ហឹម យន់* | 012 947 022 |
| ១០ | *បណ្ដាញយុវជនកម្ពុជា (CYN)* | *លោក ទឹម ម៉ាឡៃ* | 017 990 689 |
| ១១ | *សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)* | *លោក ថេង សាវឿន* | 015 225 088 |
| ១២ | *អង្គការសមធម៌កម្ពុជា (EC)* | *លោក អៀង វុទ្ធី* | 012 791 700 |
| ១៣ | *គណៈកម្មាធិការ ដើម្បីការបោះឆ្នោត ដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)* | *លោក គល់ បញ្ញា* | 012 942 017 |
| ១៤ | *ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF)* | *លោក សៀ ភារម្យ* | 012 852 325 |
| ១៥ | *សមាគម ឥន្ទ្រទេវី (IDA)* | *លោកស្រី ឌី វដ្ឋា* | 012 897 161 |
| ១៦ | *សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)* | *លោក វន់ ពៅ* | 012 534 796 |
| ១៧ | *អង្គការយេនឌ័រ និងអភិវឌ្ឍន៍នៅកម្ពុជា (GADC)* | *លោកស្រី រស់ សុភាព* | 012 627 857 |
| ១៨ | *អង្គការមាតាធម្មជាតិ* | *លោក អាឡិចហ្សង់ដ្រូ* | |

| | | | |
|---|---|---|---|
| | | ហ្គុនហ្សាឡេហ្ស | |
| ១៩ | អង្គការពន្លកខ្មែរ | លោក អាង ជាតិឡោម | 012 517943 |
| ២០ | សមាគមផាងត្នោត (STT) | លោក អ៊ី សារុំ | 012 836 533 |
| ២១ | អង្គការស្ត្រីខ្មែរ | លោកស្រី អរុណា រស្មី | 012 236 653 |
| ២២ | អង្គការ សីលការ | លោកស្រី ធីតា ឃឹះ | 012 83 84 64 |